ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ៦៩/២០២៦ កបទ.សអ

សេចក្ដីប្រកាសព័ត៌មាន

# បទបង្ហាញជូនអង្គទូតស្ដីពីការបញ្ចប់អនុស្សរណៈនៃការយោគយល់គ្នាឆ្នាំ២០០១ របស់ថៃ និងការវិវត្តថ្មីនៃបញ្ហាព្រំដែនកម្ពុជា-ថៃ

នៅរសៀលថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៦ **លោកជំទាវ អ៊ាត សោភា** រដ្ឋមន្ត្រីស្ដីទីនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានធ្វើបទបង្ហាញជូនប្រធាន និងតំណាងស្ថានបេសកកម្មការទូត និងអង្គការ-អន្តរជាតិនានានៅរាជធានីភ្នំពេញ អំពីការវិវត្តថ្មីៗនៃស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ ចាប់តាំងពីខែមករា ឆ្នាំនេះ ។ បទបង្ហាញនេះ ដែលមានការចូលរួមពីសមាជិកនៃស្ថានបេសកកម្មការទូត និងអង្គការអន្តរជាតិនានាប្រចាំកម្ពុជាចំនួន៤៣រូប ត្រូវបានធ្វើឡើងស្របពេលដែលប្រទេសថៃបានបញ្ចប់ដោយឯកតោភាគីនូវអនុស្សរណៈនៃយោគយល់គ្នារវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ទាក់ទងនឹងតំបន់ដែនសមុទ្រទាមទារត្រួតគ្នានៃខ្ពង់រាបបាតសមុទ្រ ( MOU-2001 )។

**លោកជំទាវ អ៊ាត សោភា** បានចាប់ផ្ដើមបទបង្ហាញដោយសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅរបស់កម្ពុជា ចំពោះកិច្ចខិតខំប្រឹងប្រែង និងការចូលរួមចំណែករបស់ប្រទេសសមាជិកអាស៊ាន និងប្រទេសជាដៃគូអាស៊ាន ក្នុងការសម្រេចបាននូវកិច្ចព្រមព្រៀងបទឈប់បាញ់ និងការដោះស្រាយវិវាទរវាងកម្ពុជា និងថៃដោយសន្តិវិធី។ **លោកជំទាវ** បានគូសបញ្ជាក់អំពីតួនាទីដ៏សំខាន់របស់ប្រទេសម៉ាឡេស៊ី និងហ្វីលីពីន ក្នុងនាមជាអតីតប្រធានអាស៊ាន និងប្រធានអាស៊ានបច្ចុប្បន្ន ព្រមទាំងការចូលរួមចំណែកយ៉ាងសំខាន់របស់ប្រទេសចិន និងសហរដ្ឋអាម៉េរិក ក្នុងការសម្របសម្រួលឱ្យមានបទឈប់បាញ់ និងជំរុញកិច្ចខិតខំប្រឹងប្រែង ដើម្បីស្ដារទំនុកចិត្ត និងទំនាក់ទំនងជាប្រក្រតីឡើងវិញរវាងកម្ពុជា និងថៃ។

**លោកជំទាវ** ក៏បានថ្លែងអំណរគុណដល់ប្រទេសហ្វីលីពីនផងដែរ ចំពោះកិច្ចសម្របសម្រួល ក្នុងការរៀបចំកិច្ចប្រជុំត្រីភាគីរវាងថ្នាក់ដឹកនាំនៃប្រទេសហ្វីលីពីន កម្ពុជា និងថៃ នៅក្រៅកិច្ចប្រជុំកំពូលអាស៊ាន ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៧-៨ ខែឧសភា ឆ្នាំ២០២៦ នៅកោះសេប៊ូ។ **លោកជំទាវ** បានសម្ដែងក្ដីសង្ឃឹមថា កិច្ចប្រជុំនេះនឹងទទួលបានលទ្ធផលសំខាន់ៗ និងឈានទៅរកការបន្ធូរបន្ថយស្ថានការណ៍បន្ថែមទៀត។ **លោកជំទាវ** បានស្វាគមន៍ចំពោះប្រទេសហ្វីលីពីនដែលបានទទួលតួនាទីជាប្រធានប្ដូរវេននៃក្រុមអ្នកសង្កេតការណ៍អាស៊ាន ( AOT ) កាលពីចុងខែមុន។

អាសយដ្ឋានៈ លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

**លោកជំទាវរដ្ឋមន្ត្រីស្តីទី**បានបញ្ជាក់សាជាថ្មីនូវការសោកស្តាយ និងការខកចិត្តយ៉ាងខ្លាំងរបស់កម្ពុជា ចំពោះការសម្រេចរបស់ប្រទេសថៃ ក្នុងការលុបក្របខ័ណ្ឌទ្វេភាគីតែមួយគត់ ដែលបានព្រមព្រៀងគ្នារវាងកម្ពុជា និងថៃ សម្រាប់ដោះស្រាយដោយសន្តិវិធីចំពោះតំបន់ទាមទារដែនសមុទ្រត្រួតគ្នា (OCA) និងសម្រាប់កំណត់ព្រំដែនដែនសមុទ្រ ស្របតាមច្បាប់អន្តរជាតិ។ **លោកជំទាវ** បានបញ្ជាក់ថា កម្ពុជាបានជូនដំណឹងជាផ្លូវការដល់ប្រទេសថៃអំពីការសម្រេចរបស់ខ្លួន ក្នុងការស្វែងរកដំណោះស្រាយ ចំពោះការទាមទារតំបន់ដែនសមុទ្រត្រួតគ្នានេះ តាមរយៈយន្តការផ្សះផ្សាដោយបង្ខំ ក្រោមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (UNCLOS)។

ដើម្បីផ្តល់ជាទស្សនៈទានទាក់ទងនឹងទំហំ និងវិសាលភាព នៃបញ្ហាដែលតម្រូវឱ្យមានការដោះស្រាយជាបន្ទាន់ ដើម្បីស្តារសន្តិភាព និងទំនាក់ទំនងភាពជាអ្នកជិតខាងប្រកបដោយសុខដុមរមនារវាងកម្ពុជា និងថៃឡើងវិញ **លោកជំទាវ** ក៏បានសម្របសម្រួលឱ្យមានការធ្វើបទបង្ហាញស្តីពីស្ថានការណ៍បច្ចុប្បន្ននៃតំបន់ព្រំដែនរវាងប្រទេសទាំងពីរ បន្ទាប់ពីបទឈប់បាញ់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ **លោកជំទាវរដ្ឋមន្ត្រីស្តីទី** បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តដ៏មុតមាំរបស់កម្ពុជាក្នុងការស្វែងរកដំណោះស្រាយជម្លោះព្រំដែនទាំងអស់ជាមួយប្រទេសថៃ តាមរយៈមធ្យោបាយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងទ្វេភាគីដែលមានស្រាប់ ព្រមទាំងប្រកាន់ខ្ជាប់នូវជំហរជាគោលការណ៍របស់ខ្លួនថា ព្រំដែនមិនត្រូវបានផ្លាស់ប្តូរដោយការប្រើកម្លាំងនោះឡើយ។

ថ្ងៃពុធ ៥រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៦